01188586



**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jan-2016, 09:53
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

**សំណើរបស់ នួន ជា សុំដកសាក្សីចេញពីបញ្ជីសាក្សីសម្រាប់សវនាការ**

**នៅក្នុងសំណុំរឿង ០០២/០២**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

ព្រុំ ផល្លា

Doreen CHEN

Xiaoyang NIE

Marina HAKKOU

**ចម្លងជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្ដឹង**

**រដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៨៥ សហមេធាវីការពារក្តីលោក នួន ជា (“ក្រុមមេធាវីការពារក្តី”) តទៅនេះសូមស្នើអង្គជំនុំជម្រះសាលាដំបូង ដកសាក្សី សៅ វ៉ន ហៅ សៅ ពក (2-TCW-989)-សាក្សីដែលត្រូវបានស្នើឡើងដោយក្រុមមេធាវីការពារក្តី-ពីបញ្ជីសាក្សីដែលត្រូវបានយល់ព្រមដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២។ សៅ វ៉ន (2-TCW-989) បច្ចុប្បន្ននេះគ្រោងចូលខ្លួនជាសាក្សីតែម្នាក់គត់សម្រាប់សវនាការវគ្គដែលនឹងចូលមកដល់ទាក់ទងនឹងការប្រព្រឹត្តទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តីបានដាក់សារណាសារធាតុសម្រាប់បណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១[1]។ នៅក្នុងបណ្តឹងសាទុក្ខនេះ ក្រុមមេធាវីការពារក្តីស្នើអង្គជំនុំជម្រះតុលាការកំពូល កោះហៅ សៅ វ៉ន (2-TCW-989) ចូលខ្លួនដើម្បីផ្តល់សក្ខីកម្មជាសាក្សីម្នាក់លើបណ្តឹងសាទុក្ខ[2]។

៣. នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ក្រុមមេធាវីការពារក្តីបានដាក់សំណើរួមសុំស្តាប់សាក្សីបន្ថែមចំនួន១៥រូប ទាក់ទងនឹងសហករណ៍ស្រុកត្រាំកក់ និង មន្ទីរសន្តិសុខ១០៥ស្រុកក្រាំងតាចាន់[3] សាក្សីមួយរូបក្នុងចំណោមសាក្សី១៥រូប គឺ សៅ វ៉ន (2-TCW-989)។ នៅក្នុងសំណើនោះ ក្រុមមេធាវីការពារក្តីបានពន្យល់ពីភាពពាក់ព័ន្ធនៃភស្តុតាងជាសក្តានុពលរបស់ សៅ វ៉ន (2-TCW-989) ដូចខាងក្រោម[4]

---

[1] **F16** “បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១” ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (“បណ្តឹងសារទុក្ខ”)។

[2] **F16** បណ្តឹងសាទុក្ខ នៅទំព័រ២៧០។

[3] **E346** “សំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) ស្រុកត្រាំកក់ និង ក្រាំងតាចាន់” ចុះថ្ងៃទី៣ ខែ មេសា ឆ្នាំ ២០១៥ (“សំណើសុំស្តាប់សាក្សីទាក់ទងនឹងសហករណ៍ស្រុកត្រាំកក់/មន្ទីរសន្តិសុខក្រាំងតាចាន់”)។

[4] ជើងទំព័រត្រូវបានលុប ការបញ្ជាក់នៅក្នុងភាពដើម។

នៅក្នុងដីកាដំណោះស្រាយ សហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានកំណត់ថាជាទីតាំងឧក្រិដ្ឋកម្មសំខាន់សម្រាប់ការចោទប្រកាន់ប្រឆាំង នួន ជា ទាក់ទងការប្រព្រឹត្តិទៅលើអតីតទាហាន និងអ្នករដ្ឋការរបប លន់ នល់។ សាក្សី សៅ វ៉ន ដែលត្រូវបានស្នើថ្មីនេះ អាចផ្តល់ភស្តុតាងដោះបន្ទុកពិសេស ហើយសំខាន់ លើបញ្ហានេះ។ សៅ វ៉ន មានស្រុកកំណើតនៅស្រុកត្រាំកក់។ នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គាត់បានបំពេញតួនាទីផ្សេងៗជាច្រើននៅក្នុងស្រុកនេះ។ ចាប់ពីឆ្នាំ១៩៧០ គាត់ធ្វើជាមេភូមិត្រពាំងទឹក ហើយចាប់ពីឆ្នាំ ១៩៧១ ធ្វើជាសមាជិកគណៈកម្មាធិការអប់រំកសាង ប្រជាជនឃុំ។ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គាត់បានក្លាយជាសមាជិកគណៈកម្មាធិការឃុំកំពង់ស្វាយ (ក្នុងស្រុកកៀនស្វាយ តំបន់២៥ ភូមិភាគនិរតី) ។ សៅ វ៉ន ត្រូវបានស្តាប់ចម្លើយដំបូងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រាប់សំណុំរឿង ០០៤ នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវីការពារក្តីមានសិទ្ធិចូលពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយរបស់គាត់នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ គឺ ៧២ម៉ោងមុនដល់ពេលត្រូវដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីក្នុងសំណុំរឿង ០០២/០១។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ សៅ វ៉ន បានរៀបរាប់ពីកិច្ចប្រជុំដែលគាត់បានចូលរួម "មុនឆ្នាំ ១៩៧៥" (នៅពេលដែលគាត់ប្រហែលជានៅជាកម្មាភិបាលក្នុងស្រុកត្រាំកក់) និង "ក្រោយឆ្នាំ ១៩៧៥" ដែលនៅពេលនោះ តាម៉ុក ត្រូវបានគេរាយការណ៍ថាបានបញ្ជាថា "មិនត្រូវធ្វើបាបទាហាន [លន់ នល់] ដែលមានសក្តិចាប់ពីអនុសេនីយទោ ដល់វរសេនីយឯកឡើយ"។ គាត់និយាយថា ការអនុវត្តបញ្ជានេះ "ប្រែប្រួលទៅតាមតំបន់" ។ ក្នុងតួនាទីជាគណៈកម្មាធិការអប់រំកសាងស្រុកត្រាំកក់ សៅ វ៉ន ប្រហែលជាអាចផ្តល់ព័ត៌មានស៊ីជម្រៅអំពីលក្ខណៈនៃការអប់រំកសាងនៅក្នុងស្រុកនេះ[5]។

៤. នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានឯកភាពតាមសំណើរបស់ក្រុមមេធាវីការពារក្តី សុំកោះហៅ សៅ វ៉ន (2-TCW-989)[6]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង

---

[5] **E346** សំណើសុំស្តាប់សាក្សីទាក់ទងនឹងសហករណ៍ស្រុកត្រាំកក់/មន្ទីរសន្តិសុខក្រាំងតាចាន់ នៅកថាខណ្ឌ៧។

[6] **E346/2** "សេចក្តីសម្រេចលើសំណើរួមរបស់ក្រុមមេធាវីការពារក្តី នួន ជា អនុលោមតាមវិធានផ្ទៃក្នុងសុំស្តាប់សាក្សីបន្ថែមសម្រាប់សវនាការផ្នែកទីមួយនៃសំណុំរឿង ០០២/០២ អំពីសហករណ៍ស្រុកត្រាំកក់ និង មន្ទីរសន្តិសុខក្រាំងតាចាន់ ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១៥ ។

បានលើកឡើងថា ការចូលខ្លួនរបស់ សៅ វ៉ន (2-TCW-989) នឹងត្រូវពន្យាររហូតដល់សវនាការវគ្គទាក់ទងនឹងការប្រព្រឹត្តមកលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។

៥. នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានឯកភាពលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំស្តាប់សក្ខីកម្មរបស់ សៅ វ៉ន (2-TCW-989) លើបណ្តឹងសាទុក្ខ[7]។ នៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ សៅ វ៉ន (2-TCW-989) បានផ្តល់សក្ខីកម្មមួយថ្ងៃក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ[8]។ គាត់បានពិភាក្សាយ៉ាងវែងអំពីការប្រព្រឹត្តមកលើអតីតទាហាន និងមន្ត្រីសារធារណរដ្ឋខ្មែរ ហើយជាពិសេសបញ្ជារបស់ តាម៉ុក ដែលថា "ទាហាន [លន់ នល់] ដែលមានសក្តិចាប់ពីអនុសេនីយទោ ដល់វរសេនីយឯក "មិនត្រូវធ្វើបាបឡើយ"។

៦. នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាបានដាក់សំណើមួយស្នើសុំប្រតិចារិតសវនាការទាំងអស់នៃសវនាការលើភស្តុតាងនៅក្នុងបណ្តឹងសាទុក្ខ រួមទាំងប្រតិចារិតដែលមានសក្ខីកម្មរបស់ សៅ វ៉ន (2-TCW-989) ត្រូវតែទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២[9]។ នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងយល់ព្រមលើសំណើរបស់សហព្រះរាជអាជ្ញា[10]។

៧. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងតាមសារអ៊ីម៉ែលមកភាគីថា "បន្ទាប់ពីការស្តាប់សក្ខីកម្មរបស់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម និង ចាម អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់ សៅ វ៉ន (2-TCW-989)[11] ជាសាក្សីតែមួយគត់ក្នុងអំឡុងពេលសវនាការវគ្គទាក់ទងនឹង

---

[7] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសារទុក្ខ។

[8] T. 2 កក្កដា ២០១៥ (សៅ វ៉ន **F1/1.1**)

[9] **E356** សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំទទួលយកសក្ខីកម្មពីសវនាការភស្តុតាងនៃបណ្តឹងសារទុក្ខក្នុងសំណុំរឿង ០០២/០១ នៃសវនាការថ្ងៃទី២, ៣ និង ៦ ខែ កក្កដា ឆ្នាំ២០១៥" ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥។

[10] **E356/2** "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំទទួលយកសក្ខីកម្មពីសវនាការភស្តុតាងនៃបណ្តឹងសារទុក្ខក្នុងសំណុំរឿង០០២/០១ នៃសវនាការថ្ងៃទី២, ៣ និង ៦ ខែ កក្កដា ឆ្នាំ២០១៥" ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥។

[11] សារអ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងមកភាគី ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ។

ការប្រព្រឹត្តមកលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ សក្ខីកម្មពាក់ព័ន្ធផ្សេងទៀតដែលត្រូវបានស្តាប់នៅក្នុងវគ្គលើកមុន ឬ ទំនងជាត្រូវបានផ្តល់ដោយសាក្សីដែលចូលខ្លួននៅក្នុងអំឡុងពេលសវនាការវគ្គផ្សេងទៀត។

## III. ច្បាប់ជាធរមាន

៨. វិធាន ៨៥(២) ផ្តល់អំណាចឲ្យប្រធានអង្គជំនុំជម្រះរក្សាសណ្តាប់ធ្នាប់ល្អក្នុងពេលសវនាការ។ ជាពិសេសវិធាន៨៥(១) កត់សម្គាល់ក្នុងចំណោមបញ្ហាផ្សេងទៀតថា ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅដោយសេរី" ហើយត្រូវបានអនុញ្ញាតឲ្យ "បដិសេធនូវរាល់និតីវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត"។

## IV. អំណះអំណាង

៩. ក្នុងអំឡុងពេលនៃការសួរតទល់ សៅ វ៉ន (2-TCW-989) លើបណ្តឹងសារទុក្ខ ក្រុមមេធាវីការពារក្តីអាចដោះស្រាយបញ្ហាពាក់ព័ន្ធទាំងមូលដែលខ្លួនបានស្វែងរកពីចូលខ្លួនរបស់ សៅ វ៉ន (2-TCW-989) នៅក្នុងសវនាការនៅក្នុងសំណុំរឿង ០០២/០២[12] ជាពិសេសការយល់ឃើញរបស់គាត់ទៅលើការប្រព្រឹត្តមកលើអតីតទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ។ បន្ថែមពីលើនេះភាគីផ្សេងទៀតក្នុងសំណុំរឿង០០២/០២ មានឱកាសតាំងសំណួរទៅលើ សៅ វ៉ន (2-TCW-989) លើបញ្ហាទាំងនោះក្នុងពេលសវនាការលើបណ្តឹងសាទុក្ខផងដែរ ហើយចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលក៏បានដាក់សំណួរមកលើសាក្សីដែរ។ ហេតុដូច្នេះមេធាវីការពារក្តីចាត់ទុកថា សក្ខីកម្មរបស់ សៅ វ៉ន (2-TCW-989) នៅសវនាការនេះ នឹងច្រំដែលជាច្រើនទៅនឹងសក្ខីកម្មរបស់គាត់លើបណ្តឹងសាទុក្ខ ដែលត្រូវបានទទួលយកជាភស្តុតាងរួចហើយនៅក្នុងសំណុំរឿង០០២/០២ ។ ដោយពិចារណាការបង្ហាញរបស់អង្គជំនុំជម្រះសាលាដំបូងថា សៅ វ៉ន (2-TCW-989) នឹងជាសាក្សីតែម្នាក់គត់ដែលត្រូវចូលខ្លួននៅក្នុងសវនាការវគ្គដែល នឹង

[12] សំណើសុំស្តាប់សាក្សីទាក់ទងនឹងសហករណ៍ស្រុកត្រាំកក់/មន្ទីរសន្តិសុខក្រាំងតាចាន់នៅកថាខណ្ឌ៧-៨។

មកដល់ទាក់ទងនឹងការប្រព្រឹត្តមកលើអតីតទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ និងការផ្លាស់ប្តូរប្រធានបទការជំនុំជម្រះនេះ អាចតម្រូវកិច្ចការច្រើនដោយភាគី ដូច្នេះក្រុមមេធាវីការពារ ក្តីយល់ឃើញថា ការចូលខ្លួនរបស់ សៅ វ៉ន (2-TCW-989) នឹងមិនសមស្របជាមួយសញ្ញាណនៃការឲ្យផលគាប់ចិត្តឡើយ។ ហេតុដូច្នេះក្រុមមេធាវីការពារក្តីសូមដកវិញនូវសំណើរបស់ខ្លួន សុំស្តាប់សក្ខីកម្ម សៅ វ៉ន (2-TCW-989) ជាសាក្សីតែម្នាក់គត់នៅក្នុងសំណុំរឿង០០២/០២ ហើយហេតុដូច្នេះស្នើសុំអង្គជំនុំជម្រះដំបូងដក សៅ វ៉ន (2-TCW-989) ពីបញ្ជីសាក្សីដែលផ្តល់សក្ខីកម្មនៅក្នុង០០២/០២។

## V. **សំណើ**

១០. អាស្រ័យទៅតាមសំអាងហេតុនានាខាងលើមេធាវីការពារក្តីសូមស្នើ អង្គជំនុំជម្រះសាលាដំបូងដកសាក្សី សៅ វ៉ន (2-TCW-989) ពីបញ្ជីសាក្សីដែលផ្តល់សក្ខីកម្មនៅក្នុង០០២/០២។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE